# ក្រមសីលធម៌

# គណបក្សនយោបាយ

## បេក្ខជន និង តំណាងគណបក្សនយោបាយ

## ឆ្នាំ ២០០៣

# មាតិកា

ទំព័រ

**I. គោលបំណង និងការប្រតិបត្តិតាម**......៣

ក. គោលបំណងនៃក្រមសីលធម៌......៣

ខ. ការប្រតិបត្តិតាមក្រមសីលធម៌......៣

គ. វិសាលភាពនៃសិទ្ធិនិងសកម្មភាពផ្សេងៗ......៣

ឃ. ការអនុវត្តដោយគណបក្សនយោបាយ......៤

**II. សិទ្ធិរបស់គណបក្សនយោបាយបេក្ខជន និងតំណាងគណបក្សនយោបាយ**......៤

**III. សិទ្ធិ និងភារកិច្ចរបស់តំណាងគណបក្សនយោបាយ**......៥

**IV. ករណីយកិច្ចនិងសហប្រតិបត្តិការ**......៦

**V. សិទ្ធិក្នុងការឃោសនាបោះឆ្នោត**......៧

**VI. ខ្លឹមសារនៃការឃោសនាបោះឆ្នោត**......៨

**VII. រូបភាពនៃការឃោសនាបោះឆ្នោត**......៨

ក. ការប្រជុំសាធារណៈ ការដង្ហែក្បួន......៨

ខ. ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន និងមធ្យោបាយឃោសនាបោះឆ្នោត......៩

គ. ឯកសារឃោសនា......១០

ឃ. មធ្យោបាយដឹកជញ្ជូនអ្នកបោះឆ្នោត......១០

**VIII. អំពើហិង្សា និងការបំភិតបំភ័យ**......១១

**IX. សំណូក និងសគុណ**......១១

# I. គោលបំណង និងការប្រតិបត្តិតាម

## ក. គោលបំណងនៃក្រមសីលធម៌

គោលបំណងនៃក្រមសីលធម៌សំរាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ (ក្រមសីលធម៌) គឺដើម្បី ផ្តល់លទ្ធភាពឱ្យគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្ស នយោបាយសំរេចបាននូវ ៖

- ការបោះឆ្នោតដែលធ្វើឡើងទៅតាមច្បាប់ស្តីពីការបោះ ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទប្បញ្ញត្តិផ្សេងៗរបស់ច្បាប់នេះ ។
- ការបោះឆ្នោតមានលក្ខណៈសេរីត្រឹមត្រូវ និងយុត្តិធម៌ ដែលទទួលយកបាន ដោយប្រជាពលរដ្ឋកម្ពុជា ដោយ គណបក្សនយោបាយចូលរួមបោះឆ្នោត និងដោយ សហគមន៍អន្តរជាតិ ។
- ការបោះឆ្នោតប្រព្រឹត្តទៅដោយគ្មានអំពើហិង្សាគ្មានការ បង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ។

## ខ. ការប្រតិបត្តិតាមក្រមសីលធម៌

១. គ្រប់គណបក្សនយោបាយទាំងអស់ដែលបានចុះ បញ្ជីបោះឆ្នោត បេក្ខជន និងតំណាងគណបក្ស នយោបាយទាំងអស់ត្រូវប្រតិបត្តិតាមក្រមសីលធម៌ នេះ ។

២. ការប្រតិបត្តិតាមក្រមសីលធម៌នេះ ត្រូវធ្វើពេញមួយ ដំណើរការបោះឆ្នោត ។ ដំណើរការបោះឆ្នោតចាប់ ផ្តើមនៅពេលដែលកាលបរិច្ឆេទបោះឆ្នោតត្រូវបាន ប្រកាស ហើយបន្តរហូតដល់លទ្ធផលចុងក្រោយត្រូវបានប្រកាសជាផ្លូវការ ។តំណាងគណបក្សនយោបាយ គឺជាភ្នាក់ងារគណបក្សនយោបាយ ដែលបានតែងតាំង ដោយគណបក្ស ហើយត្រូវបានទទួលការអនុញ្ញាតពី គ.ជ.ប ដើម្បី សង្កេតមើលការបោះឆ្នោត ។តំណាងគណបក្សនយោបាយក៏ត្រូវបានរាប់បញ្ចូល ផងដែរនូវអ្នកដែលមានមុខតំណែងក្នុងគណបក្ស នយោបាយ ព្រមទាំងអ្នកដែលត្រូវបានតែងតាំង ដោយគណបក្សនយោបាយ នៅក្នុងកិច្ចការណាមួយ របស់គណបក្ស ។

## គ. វិសាលភាពនៃសិទ្ធិ និងសកម្មភាពផ្សេងៗ

សិទ្ធិទាំងឡាយ និងសកម្មភាពទាំងអស់នៅក្នុងក្រមសីលធម៌ នេះ គឺស្របគ្នាទៅនឹងរដ្ឋធម្មនុញ្ញ និងល័ក្ខខ័ណ្ឌចាំបាច់ និង នីតិវិធីផ្សេងៗ ដែលមាននៅក្នុងច្បាប់បោះឆ្នោត ។ ច្បាប់ ឬផល ប្រយោជន៍ផ្សេងទៀត ដែលទាក់ទិនដល់សន្តិសុខជាតិនិងរបៀបរៀប រយសាធារណៈ អាចបដិសេធចោលនូវសិទ្ធិ និងសកម្មភាពទាំងនេះ។

## ឃ. ការអនុវត្តដោយគណបក្សនយោបាយ

១. គណបក្សនយោបាយនីមួយៗ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ ត្រូវប្តេជ្ញាចិត្ត ប្រតិបត្តិ តាម និងគាំទ្រច្បាប់បោះឆ្នោត និងត្រូវណែនាំដល់ បុគ្គលិក សមាជិក និងអ្នកគាំទ្ររបស់ខ្លួន ឱ្យអនុវត្ត ដូចគ្នាដែរ ។

២. គណបក្សនយោបាយនីមួយៗ បេក្ខជន និង តំណាងគណបក្សនយោបាយទាំងអស់ ត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម គាំទ្រ និងអនុវត្តក្រមសីលធម៌នេះ និងណែនាំដល់ បុគ្គលិក សមាជិក និងអ្នកគាំទ្រ របស់ខ្លួនឱ្យអនុវត្តដូចគ្នាដែរ ។

៣. គណបក្សនយោបាយនីមួយៗ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ ត្រូវប្តេជ្ញាចិត្ត ចាត់វិធានការវិជ្ជមានជាបន្ទាន់ ដើម្បីរារាំងបុគ្គលិក សមាជិកនិង អ្នកគាំទ្ររបស់ខ្លួនពី ៖

- ការរំលោភច្បាប់បោះឆ្នោត ឬក្រមសីលធម៌
- ការប្រព្រឹត្តបទល្មើសណាមួយ ដែលទាក់ទង ដល់ច្បាប់បោះឆ្នោត ឬក្រមសីលធម៌ ។

៤. គណបក្សនយោបាយនីមួយៗ បេក្ខជននិងតំណាង គណបក្សនយោបាយទាំងអស់ ត្រូវប្តេជ្ញាចិត្តក្នុងការផ្តល់ការគាំទ្រឱ្យបានទូលំទូលាយ និងការផ្សព្វ ផ្សាយជាសាធារណៈ អំពីច្បាប់បោះឆ្នោត និងក្រម សីលធម៌ ។

# II. សិទ្ធិរបស់គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយ

១. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ មានសិទ្ធិជាមូលដ្ឋានពេញលេញ និងស្មើភាពចូលរួមក្នុងការបោះឆ្នោត ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ រួមទាំងសិទ្ធិក្នុងការឃោសនាបោះឆ្នោតផង ។

២. សិទ្ធិជាមូលដ្ឋានពេញលេញ និងស្មើភាពចូលរួម ក្នុងការបោះឆ្នោត គឺសិទ្ធិសុំចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះសំរាប់ ការបោះឆ្នោត សិទ្ធិចូលរួមក្នុងការឃោសនាបោះឆ្នោត សិទ្ធិសង្កេតមើលការបោះឆ្នោត សិទ្ធិប្តឹង ជំទាស់ សិទ្ធិទទួលយកលទ្ធផលនៃការបោះឆ្នោត សិទ្ធិរួមសហការ និងបញ្ចេញយោបល់ និងសិទ្ធិ ការពារនូវសិទ្ធិទាំងនេះ ។

៣. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ មិនត្រឹមតែមាន សិទ្ធិ និងសេរីភាពផ្ទាល់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែត្រូវ គោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃផងដែរ ។

៤. តំណាងគណបក្សនយោបាយ និងបេក្ខជនទាំង អស់ អាចសង្កេតមើលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់ និងការ ផ្ទៀងផ្ទាត់សន្លឹកឆ្នោត ប៉ុន្តែមិនត្រូវជ្រៀតជ្រែកទៅក្នុងដំណើរការទាំងនេះទេ ។

៥. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ អាចប្តឹងតវ៉ា ឬប្តឹងជំទាស់តាមនីតិវិធីដែលមានចែងក្នុងបទបញ្ជា និង នីតិវិធីរបស់ គ.ជ.ប ប្រសិនបើយល់ឃើញថាការបោះឆ្នោតគ្មានភាពសេរី និងមិនត្រឹមត្រូវ ។

៦. គណបក្សនយោបាយ បេក្ខជន មន្ត្រី និងតំណាង គណបក្សនយោបាយទាំងឡាយ ត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ដែលមាន លក្ខណៈ សេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

## III. សិទ្ធិ និងភារកិច្ចរបស់តំណាងគណបក្សនយោបាយ

តំណាងគណបក្សនយោបាយដែលត្រូវបានអនុញ្ញាតឱ្យសង្កេត មើលការបោះឆ្នោត ៖

១. មានសិទ្ធិក្នុងការសង្កេតមើលដំណើរការបោះឆ្នោត ក្នុងនាមនៃគណបក្សនយោបាយរបស់ខ្លួន ដើម្បីធានាថា ច្បាប់និងបទបញ្ជានិងនីតិវិធី ត្រូវបាន គោរព ។

២. មានសិទ្ធិមានវត្តមាននៅតាមកន្លែងចុះឈ្មោះបោះ ឆ្នោត ឬការិយាល័យបោះឆ្នោត ឬមណ្ឌលរាប់សន្លឹកឆ្នោត ដែលខ្លួនបានទទួលការអនុញ្ញាតទៅ តាមទីកន្លែង និងពេលវេលា ដែលបានកំណត់ដោយអាជ្ញាធរបោះឆ្នោត ។

៣. មានសិទ្ធិចោទជាសំណួរលើពត៌មានផ្សេងៗ ដែល ផ្តល់ឱ្យដោយអ្នកសុំចុះឈ្មោះបោះឆ្នោតនៅពេល ត្រូវឆ្លើយនឹងសំណួររបស់មន្ត្រីចុះឈ្មោះ ។

៤. មានសិទ្ធិចោទជាសំណួរពាក់ព័ន្ធ ដល់អាយុអ្នកសុំ ចុះឈ្មោះ និងទីកន្លែងកំណើត ឪពុកម្តាយរបស់ អ្នកសុំចុះឈ្មោះ ។

៥. មានសិទ្ធិពិនិត្យមើលឯកសារផ្សេងៗដែលបាន បង្ហាញដោយអ្នកសុំចុះឈ្មោះបោះឆ្នោត នៅពេលកំពុងសុំចុះឈ្មោះ ។

៦. មានសិទ្ធិជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើ បទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់ ។ ការជំទាស់ ត្រូវធ្វើឡើងទៅសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានចាត់តាំងឱ្យត្រួតពិនិត្យការចុះ ឈ្មោះ ឬស្មៀនឃុំ សង្កាត់ នៅពេលចុះឈ្មោះ បោះឆ្នោត ឬប្រធានការិយាល័យបោះឆ្នោត ឬ ប្រធានមណ្ឌលរាប់សន្លឹកឆ្នោតនៅពេលមានការ រំលោភ ឬបន្ទាប់ពីមាន ការរំលោភ ការជំទាស់អាច លើកដោយផ្ទាល់មាត់ និង/ឬ ទៅតាមទម្រង់ បែបបទរបស់ គ.ជ.ប ។

៧. មានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍ និងកំណត់ ហេតុមួយចំនួនអំពីការចុះឈ្មោះបោះឆ្នោត កំណត់ហេតុរបស់ការិយាល័យបោះឆ្នោត និងមណ្ឌលរាប់ សន្លឹកឆ្នោតទៅតាមទម្រង់បែបបទរបស់ គ.ជ.ប ។

៨. ត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃនៅលើ សេចក្តីប្រកាសសន្យារបស់ អ្នកតំណាងគណបក្ស នយោបាយលើទំរង់ពាក្យសុំចុះឈ្មោះតំណាង គណបក្សនយោបាយ ដើម្បីសង្កេតមើលការបោះឆ្នោត ។

៩. ត្រូវរាយការណ៍ជាមុនជូនអ្នកទទួលខុសត្រូវ ឬ ប្រធានការិយាល័យក្នុងករណីមានការផ្លាស់ប្តូររវាងតំណាងពេញសិទ្ធិ និងតំណាងបំរុង ។

១០. ត្រូវបង្ហាញប័ណ្ណសម្គាល់តំណាងគណបក្សនយោ-បាយ និងលិខិតអនុញ្ញាតដល់អ្នកទទួលខុសត្រូវចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត ឬ មណ្ឌលរាប់សន្លឹកឆ្នោតដើម្បីចេញ-ចូលក្នុងការបំពេញការងារ ។

១១. ត្រូវពាក់ប័ណ្ណសម្គាល់ក្នុងពេលបំពេញការងារ ។

១២. ត្រូវចុះហត្ថលេខាលើពាក្យបណ្តឹងតវ៉ា ប្រសិនបើ បណ្តឹងនោះត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុនៃការិយាល័យ ។

១៣. ត្រូវគោរពការសម្ងាត់នៃការបោះឆ្នោត ។

១៤. មិនត្រូវផ្តល់ការណែនាំ ឬស្តីបន្ទោសដល់អ្នកទទួល ខុសត្រូវការចុះឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោត និង រាប់សន្លឹកឆ្នោតឡើយ ។

១៥. មិនត្រូវលើកការជំទាស់ ឬដាក់ពាក្យបណ្តឹងជំទាស់ ទៅជនណាម្នាក់ក្រៅពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ នៅពេលចុះឈ្មោះបោះឆ្នោត ឬប្រធាន ការិយាល័យបោះឆ្នោត ឬប្រធានមណ្ឌលរាប់សន្លឹកឆ្នោតឡើយ។

១៦. មិនត្រូវរំលោភលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ បោះឆ្នោត ឬបទបញ្ជា និងនីតិវិធី ឬក្រុមសីលធម៌នេះឡើយ ។

១៧. មិនត្រូវជ្រៀតជ្រែកដល់ដំណើរការ ចុះឈ្មោះបោះ ឆ្នោត ឬការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀតដែលទាក់ទងនឹង ការងារបោះឆ្នោតឡើយ ។

## IV. ករណីយកិច្ច និងសហប្រតិបត្តិការ

១. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ត្រូវធានា ៖

១.១ គោរព និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវច្បាប់បោះ ឆ្នោត បទបញ្ជា និងនីតិវិធី និងក្រុមសីលធម៌នេះទាំងស្រុង ។

១.២ រួមសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ មានសមត្ថកិច្ច និងអាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតបានប្រព្រឹត្តិទៅល្អ ត្រឹមត្រូវតាមច្បាប់បោះឆ្នោត និងប្រកបដោយសន្តិសុខសុវត្ថិភាព។

១.៣ រួមសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយ អាជ្ញាធរមានសមត្ថកិច្ច ក្នុងការស៊ើបអង្កេតចំពោះភាពមិនប្រក្រតីនានា ការចោទប្រកាន់ ឬបទល្មើសណាមួយ ដែលកើតឡើង ក្នុងអំឡុងពេលនៃការបោះឆ្នោត ។

១.៤ ប្រកាន់យកវិធានការដ៏ស័ក្តសិទ្ធិ សមស្រប ដើម្បីធានានូវសុវត្ថិភាព និងសន្តិសុខដល់មន្ត្រីរៀបចំការបោះឆ្នោត និងធានាមិនឱ្យ តំណាងរបស់ខ្លួនបំភិតបំភ័យ បង្កគ្រោះថ្នាក់ ប្រមាថ មាក់ងាយ ឬគំរាមកំហែងដល់ មន្ត្រីទាំងនោះក្នុងពេលបំពេញភារកិច្ច ។

២. ក្នុងការឃោសនារបស់ខ្លួនគណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយទាំងអស់ ត្រូវធ្វើឱ្យអ្នកបោះឆ្នោតយល់ថាការបោះឆ្នោត ត្រូវធ្វើដោយសម្ងាត់ និងសុចរិត ។

៣. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ ទោះក្នុងរូបភាពណាក៏ដោយមិនត្រូវរិះគន់ ឬរើសអើងដោយប្រកាន់ជាតិ សាសន៍ ភេទ ជាតិពន្ធ ឋានៈសង្គម សាសនា ឬគាំទ្រការរិះគន់ ឬការរើសអើងលើប្រភេទណា មួយដូចខាងលើនេះឡើយ ។

៤. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយ ត្រូវយកចិត្តទុកដាក់គាំទ្រ និងសម្របសម្រួលដល់ ៖

៤.១ សិទ្ធិរបស់ព្រះសង្ឃក្នុងការចូលរួមក្នុងដំណើរ ការបោះឆ្នោត ។

៤.២ សិទ្ធិរបស់ស្ត្រីក្នុងការចូលរួមក្នុងដំណើរការ
ការបោះឆ្នោត ។

៤.៣ សិទ្ធិរបស់ស្ត្រីក្នុងការចូលរួមក្នុងការងារនិង សកម្មភាពនយោបាយក្នុងការបោះឆ្នោត ។

៤.៤ សិទ្ធិរបស់ស្ត្រីក្នុងការផ្តល់ និងទទួលពត៌មាន ត្រឹមត្រូវទាក់ទងនឹងការបោះឆ្នោត ។

## V. សិទ្ធិក្នុងការឃោសនាបោះឆ្នោត

១. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើភាពគ្នាក្នុង ៖

- ការឃោសនារកការគាំទ្រ និងរកសម្លេងឆ្នោត តែត្រូវរៀបចំឱ្យមានបរិយាកាសស្ងប់ស្ងៀម និងសុខសាន្ត ។
- ការលើកស្ទួយការឃោសនារបស់ខ្លួនតាមគ្រប់ រូបភាព និងមធ្យោបាយស្របច្បាប់ទាំងអស់ ។

២. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ មានសិទ្ធិស្មើភាពគ្នាក្នុងការទទួលបាននូវការការពារសន្តិសុខនិងសុវត្ថិភាព ក្នុងការធ្វើសកម្មភាពក្នុងដំណើរការបោះឆ្នោត។

៣. គណបក្សនយោបាយ បេក្ខជន និងតំណាង នៃ គណបក្សនយោបាយទាំងអស់ មានសិទ្ធិធ្វើសកម្មភាព ឃោសនាបោះឆ្នោតដោយសេរីក្នុងមណ្ឌលរបស់ខ្លួន ឬក្នុងទូទាំងប្រទេស ។

៤. គណបក្សនយោបាយមានឱកាសស្មើភាពគ្នា ក្នុងការ ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន របស់រដ្ឋ តាមការ រៀបចំរបស់ គ.ជ.ប ក្នុងការឃោសនាបោះឆ្នោត ។

៥. គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្ស នយោបាយ ត្រូវឈប់សំរាកនៅចន្លោះម៉ោង ១០យប់ ដល់ម៉ោង ៦ព្រឹក ។

៦. គណបក្សនយោបាយ បេក្ខជននិងតំណាងគណបក្ស នយោបាយទាំងអស់ ត្រូវគោរពឱ្យបានដាច់ខាតរយៈពេលនៃការឃោសនាបោះឆ្នោត ដែលកំណត់ដោយ ច្បាប់បោះឆ្នោត។

## VI. ខ្លឹមសារនៃការឃោសនាបោះឆ្នោត

១. ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។

២. សេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ប័ណ្ណ រូបភាព បិទផ្សាយ និងសម្ភារៈឃោសនាផ្សេងទៀត ត្រូវចៀស វាងដាច់ខាតការប្រើភាសា ឬរូបភាពរំលោភបំពាន ខ្វះសីលធម៌ ដែលមានលក្ខណៈ អុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬអំពើហិង្សា ។

៣. ក្នុងការឃោសនា ការរិះគន់គណបក្សនយោបាយដទៃ ត្រូវឆ្លុះបញ្ចាំងតែទៅលើ គោលនយោបាយ កម្មវិធីនយោបាយ និងបទពិសោធការងារ ។ ត្រូវចៀសវាងដាច់ខាតចំពោះការរិះគន់ទៅលើ បុគ្គលិកលក្ខណៈ ផ្ទាល់ របស់បុគ្គល ឬគណបក្សនយោបាយដទៃ ។

៤. គណបក្សនយោបាយ បេក្ខជន និងមន្ត្រីគណបក្ស នយោបាយទាំងអស់ ត្រូវទទួលខុសត្រូវ ផ្ទាល់លើខ្លឹមសារនិងសកម្មភាពនៃការឃោសនាបោះឆ្នោតរបស់ខ្លួន ។

## VII. រូបភាព នៃការឃោសនាបោះឆ្នោត

### ក. ការប្រជុំសាធារណៈ ការដង្ហែក្បួន

១. គណបក្សនយោបាយដែលចុះបញ្ជីឈរឈ្មោះបោះឆ្នោត បេក្ខជន និងតំណាងគណបក្ស នយោបាយ នោះ មានសិទ្ធស្មើភាពក្នុងការបើកការប្រជុំសាធារណៈ និងការដង្ហែក្បួនដោយសន្តិវិធី ដើម្បី ស្វែងរកសម្លេង ឆ្នោត ។

២. គណបក្សនយោបាយ បេក្ខជន និងតំណាងរបស់ គណបក្សនយោបាយ ដែលមានបំណង ធ្វើការប្រជុំ សាធារណៈ ឬការដង្ហែក្បួន ត្រូវជូនដំណឹងទៅ អាជ្ញាធរមានសមត្ថកិច្ច និងអាជ្ញាធរ រៀបចំបោះឆ្នោត ឃុំ សង្កាត់ ឬខេត្ត ក្រុង ដោយបញ្ជាក់ច្បាស់លាស់ ពីពេលវេលា កាលបរិច្ឆេទ ទីកន្លែង ដែលមានបំណង ធ្វើសកម្មភាពយ៉ាងតិចបី (០៣) ថ្ងៃ មុនពេល កំណត់ធ្វើសកម្មភាព ដើម្បីអាជ្ញាធរសហការសម្រប សម្រួល ៖

- ចាត់ចែងកិច្ចការពារសន្តិសុខ និងរបៀបរៀបរយសាធារណៈ

- ចៀសវាងការជាន់កម្មវិធី ឬទីកន្លែង ឬពេលវេលា
- ចៀសវាងការកើតឡើងជាយថាហេតុ នូវការប្រឈមមុខដាក់គ្នា ទំនាស់ និងអំពើហិង្សា ។

៣. គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្ស នយោបាយ ត្រូវយកចិត្តទុកដាក់គោរពឱ្យបានល្អ កម្មវិធី ដែលត្រូវបានសម្របសម្រួលដោយអាជ្ញាធរ ។

៤. គណបក្សនយោបាយ និងបេក្ខជន ដែលមាន បំណងជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ត្រូវធ្វើពាក្យសុំទៅ អ្នកគ្រប់គ្រងទីកន្លែងនោះបី (៣)ថ្ងៃយ៉ាងតិចមុន ថ្ងៃប្រជុំឃោសនា ហើយត្រូវចម្លងពាក្យសុំនេះមួយ ច្បាប់ផ្ញើទៅ គឃ/សប ។

៥. គណបក្សនយោបាយ បេក្ខជន និងតំណាងនៃ គណបក្សនយោបាយមិនត្រូវ ៖

- រារាំង រំខាន ឬបង្កើតពាក្យចចាមអារាម នាំឱ្យ មានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាជន មិនឱ្យចូលរួមក្នុងការប្រជុំ ការហែក្បួនណាមួយ របស់គណបក្ស ឬបេក្ខជនដទៃទៀយ ។
- ប្រើប្រាស់ ឬយល់ព្រមឱ្យប្រើប្រាស់នូវភាសា ការបង្ហាញ ឬសកម្មភាពណាមួយ ឬគ្រឿងញៀន ឬសុរា ដែលអាចជំរុញ ឬលើកទឹក ចិត្តដល់ការប្រព្រឹត្តអំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យណាមួយឡើយ ។
- យល់ព្រមដាក់តាំង ឬបង្ហាញ ឬចែកចាយ ការពណ៌នាអំពីជាការវាយប្រហារ ឬអាវុធនោះឡើយ ។

## ខ. ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន និងមធ្យោបាយឃោសនាបោះឆ្នោត

១. ប្រព័ន្ធផ្សព្វផ្សាយពត៌មានរបស់រដ្ឋដូចជា វិទ្យុ ទូរទស្សន៍ និងមធ្យោបាយឃោសនាផ្សេងទៀតដូចជាប្រព័ន្ធផ្សព្វ ផ្សាយសាធារណៈ (រួមទាំងឧត្ប្លោសនស័ព្ទផង) មន្ត្រីរាជការស៊ីវិល កងទ័ព នគរបាល មធ្យោបាយ ដឹកជញ្ជូន សម្ភារៈការិយាល័យ ឬសម្ភារៈបរិក្ខារ របស់រដ្ឋផ្សេងទៀត មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ដើម្បីជាប្រយោជន៍របស់គណបក្ស ឬបេក្ខជនឡើយ។

២. គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្ស នយោបាយនីមួយៗ ត្រូវប្រើប្រាស់ឱកាស និងពេល វេលាផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋទៅ តាមគោលការណ៍ និងទិសដៅរបស់ គ.ជ.ប ដែល ផ្អែកទៅលើសិទ្ធិស្មើភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វ ផ្សាយពត៌មាន ។

៣. គ្រប់គណបក្សនយោបាយទាំងអស់ អាចធ្វើការផ្សព្វ ផ្សាយពត៌មាន ឬគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោតតាមការជួល ប្រព័ន្ធផ្សព្វផ្សាយពត៌មានឯកជន ដែលត្រូវបើកចំហរដោយស្មើភាពចំពោះគ្រប់គណបក្សនយោបាយ ។

៤. ការចាក់ផ្សព្វផ្សាយពត៌មាន ឬ ការប្រើប្រព័ន្ធផ្សព្វ ផ្សាយតាមផ្លូវសាធារណៈណាមួយ ដោយសំលេង ខ្លាំងៗ លុបលើសំលេងរបស់គណបក្ស ឬបេក្ខជន ដទៃទៀតត្រូវហាមឃាត់ ។

៥. សកម្មភាពឃោសនា ដោយបំពងសំលេង ត្រូវហាម ឃាត់ចាប់ពីម៉ោង ១២ថ្ងៃត្រង់ដល់ម៉ោង ២ រសៀល និងចាប់ពីម៉ោង ១០យប់ ដល់ម៉ោង ៦ភ្លឺ ។

## គ. ឯកសារឃោសនា

១. គណបក្សនយោបាយ ភ្នាក់ងារនៃគណបក្សនយោបាយ បេក្ខជន និងអ្នកគាំទ្ររបស់ខ្លួនត្រូវចៀសវាង ៖

១.១ ការប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ឬព្រះនាម ព្រះមហាក្សត្រ ឬផ្លាកសញ្ញា គ.ជ.ប ដើម្បីរកសម្លេងឆ្នោត ។

១.២ ការលួចចម្លងយកតាមសញ្ញាសម្គាល់ ឬពាក្យ ស្លោករបស់គណបក្សនយោបាយដទៃ ។

១.៣ ការបិទប័ណ្ណផ្សាយសេចក្តីថ្លែងការណ៍នយោ_ បាយ ឬឯកសារឃោសនាដទៃទៀតពីលើរបស់អ្នកដទៃ ។

១.៤ ការបក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោល នូវប័ណ្ណបិទផ្សាយសេចក្តីប្រកាសនយោបាយ ឬឯកសារឃោសនាផ្សេងទៀតរបស់អ្នកដទៃ។

១.៥ ការបិទប័ណ្ណបិទផ្សាយ សេចក្តីប្រកាស នយោបាយ ឯកសារឃោសនាដទៃទៀត ឬការចងបដានៅជុំវិញការិយាល័យបោះឆ្នោត ក្នុងចម្ងាយ ១០០ ម៉ែត្រ ។

១.៦ ហាមលើកបដាឃោសនា និងរូបសញ្ញាណា មួយដែលបង្ហាញពីការគាំទ្រគណបក្ស ឬ បេក្ខជនណាមួយឆ្លងកាត់ទទឹងផ្លូវសាធារណៈ។

២. គណបក្សនយោបាយនីមួយៗ ត្រូវប្រមូលយកវិញនូវ ប័ណ្ណបិទផ្សាយ ប័ណ្ណប្រកាស បដា ឯកសារឃោសនារបស់ខ្លួនទាំងអស់ពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេលដប់ប្រាំ (១៥)ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។

## ឃ. មធ្យោបាយដឹកជញ្ជូនអ្នកបោះឆ្នោត

១. គណបក្សនយោបាយ បេក្ខជន ឬជនណាក៏ដោយ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់មធ្យោបាយ ដឹកជញ្ជូនគ្រប់ប្រភេទរបស់រដ្ឋ រួមទាំងមធ្យោបាយដឹកជញ្ជូនយោធានិងនគរបាលក្នុងការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ ឬចេញពីការិយាល័យបោះឆ្នោតឡើយ ។

២. ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះ ឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើ ប្រាស់យានជំនិះទាំងនេះមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធ នឹងគណបក្សនយោបាយណាមួយ ។

២.១ គណបក្សនយោបាយ បេក្ខជន ឬតំណាង នៃគណបក្សនយោបាយអាចប្រើប្រាស់ ឬ អនុញ្ញាតឱ្យប្រើប្រាស់នូវមធ្យោបាយដឹក ជញ្ជូនណាមួយ ដែលគ្រប់គ្រងដោយឯកជន ខ្លួនឯងដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅ និងមក ឬដើម្បីធ្វើសកម្មភាពនយោបាយណា មួយ ។

២.២ នៅក្នុងថ្ងៃបោះឆ្នោត មធ្យោបាយដឹកជញ្ជូន នេះមិនត្រូវភ្ជាប់នូវរូបភាព ឬការផ្សព្វផ្សាយ ឃោសនាបោះឆ្នោតឡើយ ។

## VIII. អំពើហិង្សា និងការបំភិតបំភ័យ

១. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ត្រូវធានាថា ៖

១.១ មិនប្រើប្រាស់អំពើហិង្សាគ្រប់ប្រភេទ ។

១.២ មិនត្រូវធ្វើការវាយប្រហារណាមួយទៅលើ ប័ណ្ណបិទផ្សាយ ឬទីស្នាក់ការគណបក្ស នយោបាយណាមួយឡើយ ។ បំរាមនេះរួម បញ្ចូលទាំងការគំរាមកំហែង ការបំភិតបំភ័យ ការគាបសង្កត់ដោយអាវុធ ដោយផ្ទាល់ ឬ ដោយប្រើអ្នកដទៃ ឬប្រើភាសាឃោរឃៅទៅ លើសមាជិក អ្នកគាំទ្រ ឬបេក្ខជននៃគណបក្ស នយោបាយផ្សេងទៀត ។

រាល់អំពើទាំងនេះ ត្រូវបានថ្កោលទោស និង ចាត់ទុកជាការប្រាសចាកគោលការណ៍ ប្រជាធិបតេយ្យដែលគណបក្សនយោបាយ និង/ឬ បេក្ខជនទាំងអស់ត្រូវតែចៀសវាង ឱ្យបានដាច់ខាត ។

២. ការកាន់កាប់ ការប្រើប្រាស់ ឬការសំដែងឱ្យ ឃើញនូវអាវុធជាតិផ្ទុះប្រភេទណាមួយក៏ដោយ ត្រូវ ហាមឃាត់ជាដាច់ខាតនៅក្នុងការប្រជុំឃោសនានៅ
ក្នុងការហែក្បួននៅទីស្នាក់ការគណបក្សនយោបាយ នៅការិយាល័យចុះឈ្មោះ នៅពេលចុះឈ្មោះបោះឆ្នោត នៅការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត និងនៅ មណ្ឌលរាប់សន្លឹកឆ្នោត ។

## IX. សំណូក និងសគុណ

១. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ ត្រូវចៀសវាង ៖

១.១ ការប្រព្រឹត្តអំពើពុករលួយក្នុងអំឡុងពេលនៃ ការបោះឆ្នោត ។

១.២ ការផ្តល់វិភាគទាន ការជូនសគុណ ឬរង្វាន់ លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារៈ ទោះបីតាមមធ្យោបាយណាក៏ដោយ ដល់ ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុង រយៈពេលឃោសនាបោះឆ្នោត រហូតដល់ ថ្ងៃបោះឆ្នោត ដើម្បីទទួលបានការគាំទ្រ ឬ ទទួលបានសន្លឹកឆ្នោតពី ស្ថាប័ន អង្គការ ឬបុគ្គល ទាំងនោះ ។

១.៣ ការរំលោភ ឬប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឬឥទ្ធិពលដោយសន្យាណាមួយ ឬគំរាមគំហែង ដើម្បីទទួលបានសម្លេង ឆ្នោត ឬការគាំទ្រពីបុគ្គលណាម្នាក់មកលើ ខ្លួន ឬប្រឆាំងនឹងគណបក្សនយោបាយណា មួយ ឬបេក្ខជនណាម្នាក់ ។

១.៣.១ ការរំលោភមានរាប់បញ្ចូលទាំងការ ផ្តល់ឱ្យនូវអ្វីមួយ ឬការគំរាម គំហែងឱ្យទទួល ឬដកហូតអ្វីមួយ ឬការធ្វើឱ្យមិនពេញចិត្ត ។

១.៣.២ តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឬ ឥទ្ធិពលមានរាប់បញ្ចូលទាំងសិទ្ធិ អំណាច ខាងមាតាបិតា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាង សាសនា ឬខាងប្រពៃណី ។

២. គ្រប់គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ មិនត្រូវ ស្វែងរក ការគាំទ្រពី ៖

២.១ សមាជិក និងមន្ត្រីនៃ គ.ជ.ប និងគណៈកម្ម ការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ដើម្បី លើកទឹកចិត្តអ្នកបោះឆ្នោតឱ្យបោះឆ្នោត ឬ មិនបោះឆ្នោតឱ្យគណបក្សនយោបាយ ឬ បេក្ខជនណាមួយ ។

២.២ អ្នកគាំទ្ររបស់ខ្លួនឱ្យក្លែងបន្លំ ឬបំផ្លាញ សន្លឹកឆ្នោត ឬគូសកំណាត់សម្គាល់ណាមួយ លើសន្លឹកឆ្នោត ។

៣. គណបក្សនយោបាយ បេក្ខជន និងតំណាង គណបក្សនយោបាយទាំងអស់ មិនអនុញ្ញាតឱ្យ ទិញសន្លឹកឆ្នោតពីអ្នកបោះឆ្នោតឡើយ ។